SNOHOMISH HEALTH DISTRICT

## ព័ត៌មានថ្មីៗសម្រាប់និយោជិកនិងនិយោជកៈ ថ្ងៃទី ១ ខែតុលាឆ្នាំ ២០២០

កន្លែងធ្វើការនីមួយអាចមានវិធីការពារការចម្លងខុសៗគ្នា កំឡុងពេលមានជំងឺរាតត្បាតនេះ។ វាអាចធ្វើឱ្យមានការភាន់ច្រលំនិងភាពស្មុគស្មាញខ្លះសម្រាប់បុគ្គលិក អ្នកគ្រប់គ្រង និងម្ចាស់អាជីវកម្ម ។

កន្លងមក ធ្លាប់មានករណីកូវីដ-១៩ នៅកន្លែងធ្វើការក្នុងតំបន់ Snohomish ហើយវានឹងបន្តកើនឡើងទៀត បើសិនជាអាជីវកម្មនៅតែបន្តបើក ឬពង្រីកប្រតិបត្តិការ។ ក្រុមឆ្លើយតបផ្នែកអាជីវកម្មនិងម្ចាស់អាជីវកម្មរបស់មណ្ឌលសុខភាពបាននិងកំពុងធ្វើការជាមួយម្ចាស់ក្រុមហ៊ុនជាង ៨០នាក់ អំពីការផ្ទុះជម្ងឺ COVID-១៩ រួមទាំងមនុស្សរាប់សិបនាក់ទៀតលើករណីតែមួយ និងដាក់អនុវត្តវិធានការប្រុងប្រយ័ត្ននានានៅកន្លែងធ្វើការ។ មនុស្សកាន់តែច្រើនត្រឡប់ទៅធ្វើការវិញ មានន័យថាមានការទាក់ទងផ្ទាល់នឹងមានច្រើនជាងមុនផងដែរ ដែលនេះគឺជាវិធីដែលជម្ងឺអាចចម្លងរីករាលដាលទៅអ្នកផ្សេងបាន ។

យើងជម្រុញឱ្យអាជីវកម្មទាំងអស់ត្រូវប្រុងប្រយ័ត្នគ្រប់ជ្រុងជ្រោយ ដូចជា ការតម្រូវឱ្យមានម៉ាស់ ការរក្សាគម្លាតរវាងបុគ្គលិក ក៏ដូចជាអតិថិជនផងដែរ ការលាងសម្អាតដៃ សម្ភារៈ ការធ្វើឱ្យមានខ្យល់ចេញចូល ផ្តល់ជម្រើសឱ្យធ្វើការអនឡាញ បើសិនជាអាច និងធានាថាមនុស្សដែលឈឺ មិនត្រូវឱ្យមកធ្វើការនោះទេ។ នេះរួមបញ្ចូលទាំងការអនុញ្ញាតឱ្យបុគ្គលិកអាចឈប់សម្រាក និងសម្របសម្រួលឱ្យពួកគេនៅសម្រាកនៅផ្ទះ រហូតដល់ជាសះស្បើយឡើងវិញ ។

ការបង្កើតកន្លែងធ្វើការដែលមានសុវត្ថិភាព និងអនាម័យល្អ គឺមានសារៈសំខាន់ណាស់ ប្រសិនបើយើងចង់បង្កើននិងរក្សាសកម្មភាពអាជីវកម្មឱ្យនៅដំណើការធម្មតា ក្នុងកំឡុងពេលមានជំងឺរាតត្បាតនេះ ។

ទោះយ៉ាងណាក៏ដោយ ទោះបីជាមានការខិតខំប្រឹងប្រែងល្អបំផុតក៏ដោយ ក៏ករណីឆ្លងអាចនឹងកើតមានឡើងដែរ។ ជំងឺនេះវាបាននៅជុំវិញពួកយើងរួចទៅ ។

វាចាំបាច់ណាស់ដែលម្ចាស់អាជីវកម្មត្រូវធ្វើការជាមួយអាជ្ញាធរសុខភាពសាធារណៈ ដើម្បីដោះស្រាយករណីឆ្លងនៅកន្លែងធ្វើការ និងកាត់បន្ថយលទ្ធភាពនៃការឆ្លងរីករាលដាលឡើងកាន់តែអាក្រក់បន្ថែមទៀត ។

## ការជូនដំណឹងរបស់ម្ចាស់អាជីវកម្ម និងការស្វែងរកអ្នកប៉ះពាល់ផ្ទាល់

នៅពេលនរណាម្នាក់ដែលមានតេស្តវិជ្ជមាន COVID-19 មន្ត្រីសុខភាពសាធារណៈចាប់ផ្តើមដំណើរការនៃការជូនដំណឹងទៅម្ចាស់អាជីវកម្ម

ក៏ដូចជាការស្វែងរកអ្នកប៉ះពាល់ផ្ទាល់។ ដំណើរការនេះមាន ៣ ជំហានសំខាន់។ ទីមួយ អ្នកស៊ើបអង្កេតស្វែងរកអ្នកប៉ះពាល់ផ្ទាល់ជាមួយអ្នកមានវិជ្ជមាន និងធ្វើការសម្ភាសន៍ពួកគេ។

ការសម្ភាសន៍នេះ ក៏ចាត់ទុកជាជំហានដំបូងនៃការប៉ះពាល់ផ្ទាល់ផងដែរ។ អ្នកស៊ើបអង្កេតករណីនោះនឹងសួរថាតើ បុគ្គលនោះមានការងារធ្វើដែរឬទេ និងថាតើពួកគេមានធ្វើការទេអំឡុងពេលដែលចាប់ផ្តើមមានរោគសញ្ញាកូវីដ១៩។ រយៈពេលលទ្ធភាពនៃការឆ្លងរាលដាល អាចពីរថ្ងៃមុន និងយ៉ាងហោចណាស់ ១០ថ្ងៃក្រោយចាប់ផ្តើមរោគសញ្ញា។ ប្រសិនបើនរណាម្នាក់មិនមានរោគសញ្ញា អំឡុងពេលមានវិជ្ជមានទេ គឺលទ្ធភាពនៃការឆ្លងត្រូវរាប់ចាប់ពីពីរថ្ងៃមុនតេស្ត និង១០ក្រោយ បន្ទាប់ពីពេលធ្វើតេស្ត។

បើសិនបើបុគ្គលិកមានវត្តមាននៅកន្លែងធ្វើការ អ្នកស៊ើបអង្កេតនឹងប្រឹក្សាជាមួយមន្ត្រីជំនាញជម្ងឺឆ្លង ដើម្បីកំណត់ថាតើនេះជាករណីឆ្លងធម្មតា ឬការឆ្លងរីករាលដាលនៅកន្លែងធ្វើការ។

ការឆ្លងរីករាលដាលកូវីដនៅកន្លែងធ្វើការ គឺនៅពេលដែលបុគ្គលិកពីរ ឬច្រើន ដែលមិនមានសមាជិកគ្រួសារបានឆ្លងកូវីដក្នុងរយៈពេល ១៤ថ្ងៃ ហើយបានតេស្តវិជ្ជមានកូវីដ១៩។ លើកលែងតែបុគ្គលិកធ្វើការនៅកន្លែងថែទាំមនុស្សរយៈពេលយូរ ដែលនៅពេលមាននរណាម្នាក់ឆ្លង គេនឹងចាត់ទុកកន្លែងថាបានផ្ទុះការឆ្លងរាលដាល ដោយសារតែទីកន្លែងនោះមានហានិភ័យខ្ពស់។

បើសិនករណីណាមួយ ត្រូវបានកំណត់ថាជាការផ្ទុះរីករាលដាលហើយ មន្ត្រីសុខាភិបាលនឹងអញ្ជើញម្ចាស់អាជីវកម្មមកបញ្ជាក់ថាតើ បុគ្គលិកដែលមានឆ្លងកូវីដ ពិតជាបានធ្វើការឱ្យគេដែរឬទេ និងថាតើម្ចាស់អាជីវកម្មដឹងរឿងនេះដែរឬទេ។ ពាក្យស្នើសុំចាត់បុគ្គលណាម្នាក់ដើម្បីឱ្យមន្ត្រីសុខាភិបាលទំនាក់ទំនងទៅ នៅពេលមានការផ្ទុះការឆ្លងអាច អាចរកបាននៅក្នុង www.snohd.org/employernotifications ។

អ្នកសម្ភាសន៍នឹងទាមទាររកបញ្ជីឈ្មោះអ្នកដែលបានធ្វើការក្នុងអំឡុងពេល ២៤ម៉ោងជាមួយនឹងបុគ្គលិកដែលបានឆ្លងកូវីដ១៩។ អ្នកដែលត្រូវរាប់បញ្ចូលមានដូចខាងក្រោម៖

- បាននៅជិតនឹងអ្នកមានកូវីដ១៩ ក្នុងចម្ងាយ 6 feet ក្នុងរយៈពេល ១៥ ឬយូរជាងនេះ (ដោយរាប់បញ្ចូនទាំងពេលញ៉ាំអាហារ ឬពេលសម្រាក) ឬ
- បានប្រើសម្ភារៈរួមគ្នា ដោយមិនបានសម្លាប់មេរោគ ឬប្រើប្រាស់ដោយគ្មានស្រោមដៃការពារ ឬ
- ជិះឡានដឹកបុគ្គលិករួមគ្នានៅកន្លែងធ្វើការ។

សូមធ្វើតាមសេចក្តីណែនាំ អំពីការរក្សាព័ត៌មានឱ្យមានសុវត្ថិភាពនៅពេលបញ្ជូនឯកសារទៅមណ្ឌលសុខភាព។ សូមមេត្តាកុំផ្ញើតាមរយៈអ៊ីម៉ែល ពីព្រោះការបញ្ជូនព័ត៌មានសុខភាពតាមរយៈប្រព័ន្ធការពារមិនច្បាស់លាស់ ឬមិនមែនច្រកចូលផ្លូវការ គឺល្មើសនឹងច្បាប់ឯកជនភាព។ បុគ្គលនីមួយៗ នឹងត្រូវបានទាក់ទងដោយអង្គភាព

សុខាភិបាល ដើម្បីពិភាក្សាអំពី ស្ថានភាពដែលបុគ្គលនោះបានប៉ះពាល់ផ្ទាល់នឹងអ្នកមានកូវីដ១៩ របៀបរបបនិងរយៈពេលដែលត្រូវឱ្យនៅដោយឡែក និងឆ្លើយនឹងសំនួរផ្សេងៗ។

មន្ត្រីសុខាភិបាលនឹងជជែកជាមួយម្ចាស់អាជីវកម្មអំពីវិធានការសុវត្ថិភាពសម្រាប់បុគ្គលិក។ វាអាចរាប់បញ្ចូលការត្រួតពិនិត្យបុគ្គលិក ការសម្អាតនិងការសម្លាប់មេរោគ ឬការផ្តល់សម្ភារៈសម្រាប់ការពារ។

ចុងក្រោយ គឺក្រុមការងារត្រួតពិនិត្យទីតាំងនឹងធ្វើការជាមួយម្ចាស់អាជីវកម្ម។ ក្រុមការងារនេះមិនមែនចុះធ្វើអធិការកិច្ចទេ។ វាគ្រាន់តែជាការសន្ទនាគ្នាផ្តោតទៅលើការណែនាំនិងការជម្រុញវិធានប៉ុណ្ណោះ។ ក្រុមការងារនឹងពិនិត្យទីតាំង ពិភាក្សាអំពីស្តង់ដារសុវត្ថិភាព និងផ្តល់ជាអនុសាសន៍ផ្សេងៗ។ បើទីតាំងមានផ្ទុះការរីករាលដាល ការត្រួតពិនិត្យទីតាំងត្រូវធ្វើជាចាំបាច់។ បើទីតាំងមានការឆ្លងតែមួយករណី ការត្រួតពិនិត្យទីតាំងអាចធ្វើ ឬមិនធ្វើ។

បុគ្គលិកមានសិទ្ធិទទួលព័ត៌មានថាខ្លួនមានវិជ្ជមានកូវីដផ្ទាល់ពីកន្លែងធ្វើតេស្ត មុនមណ្ឌលសុខភាពទទួលបានពីកន្លែងធ្វើតេស្ត។ បើសិនជាបុគ្គលិកបានជូនដំណឹងទៅអ្នកគ្រប់គ្រងថា ខ្លួនមានកូវីដ១៩ ម្ចាស់អាជីវកម្មអាចផ្ញើអ៊ីម៉ែលទៅ [CDQuestions@snohd.org](mailto:CDQuestions@snohd.org) ឬខល 4253395278។ ជាថ្មីម្តងទៀត សូមកុំផ្ញើព័ត៌មានផ្ទាល់ខ្លួនរបស់បុគ្គលិកតាមអ៊ីម៉ែល។ នេះជាឧទាហរណ៍ខ្លឹមសារដែលអ្នកគួរផ្ញើមកយើង «មានបុគ្គលិកម្នាក់មានវិជ្ជមានកូវីដ១៩ នៅទីតាំងរបស់ខ្ញុំ។ ខ្ញុំជាអ្នកគ្រប់គ្រង ឬម្ចាស់ទីតាំង ឬអ្នកត្រួតពិនិត្យ សូមសុំការប្រឹក្សាពាក់ព័ន្ធនឹងករណីនេះ ជាមួយមន្ត្រីសុខាភិបាល។ លេខរបស់ខ្ញុំ XXX-XXX-XXX។

## សម្រាប់បុគ្គលិក តើអ្វីនឹងកើតបើខ្ញុំឈឺ តែខ្ញុំពុំមានសិទ្ធិឈប់ដោយមានបៀវត្សគ្រប់គ្រាន់ ឬគេឱ្យខ្ញុំត្រូវមកធ្វើការ?

ការការពារផ្នែកច្បាប់ ត្រូវបានអនុវត្តនិងបន្តគាំទ្របុគ្គលិកនានា អំឡុងពេលការឆ្លងរីករាលដាលនេះ។ នៅរដ្ឋ Washington មានយន្តការមួយចំនួនត្រូវបានដាក់ឱ្យអនុវត្ត ដើម្បីជួយបុគ្គលិកដែលមានកូវីដ១៩។ ក្នុងនោះរួមមាន ការផ្តល់ជូនសិទ្ធិឈប់ដោយមានបៀវត្សបន្ថែម និងយន្តការថ្មីមួយទៀតគឺ **[ការការពារសិទ្ធិបុគ្គលិកក្នុងករណីបន្ទាន់អាសន្ន]()**។

បន្ថែមលើបទបញ្ញាកម្រិតរដ្ឋខាងលើ ច្បាប់ស្តីពី [Families First Coronavirus (FFCRA)]() បានផ្តល់ការការពារនិងអត្ថប្រយោជន៍បន្ថែមទៀតជូនបុគ្គលិក។

ម្ចាស់អាជីវកម្ម «មិនអាចបញ្ឈប់ការងារ ដាក់ពិន័យ ឬរើសអើស» ចំពោះបុគ្គលិកដែលបានប្រើប្រាស់សិទ្ធិរបស់ខ្លួនឡើយ យោងទៅតាមច្បាប់ខាងលើ។

ច្បាប់ខាងលើ [FFCRA]() បុគ្គលិកមានសិទ្ធិឈប់សម្រាកដោយមានបៀវត្ស បើសិនជាពួកគេមិនអាចមកធ្វើការដោយមូលហេតុដូចខាងក្រោម៖

- ត្រូវបានគេតម្រូវឱ្យនៅផ្ទះ តាមបទបញ្ញាស្តីពីការដាក់ឱ្យនៅដោយឡែក ([បទបញ្ញារបស់ Snohomish County]()) ឬត្រូវថែរក្សាបុគ្គលម្នាក់ទៀតដែលត្រូវគេតម្រូវឱ្យនៅផ្ទះ៖

- ត្រូវបានមន្ត្រីសុខាភិបាលណែនាំឱ្យនៅដោយឡែកពីគេ ឬត្រូវថែរក្សាបុគ្គលដែលត្រូវឱ្យនៅដោយឡែកពីគេ
- មានរោគសញ្ញាកូវីដ១៩ និងកំពុងរង់ចាំលទ្ធផល
- កំពុងមើលថែកុមារ ដោយមូលហេតុសាលា ឬកន្លែងមើលថែកុមារត្រូវបានបិទបណ្តោះអាសន្នដោយមូលហេតុកូវីដ១៩ ឬ
- កំពុងជួបការលំបាកប្រហាក់ប្រហែលនឹងស្ថានភាពខាងលើនេះ (ដូចបានលើកឡើងដោយរដ្ឋមន្ត្រីសុខាភិបាល និងធនធានមនុស្ស និងលេខាធិការទទួលបន្ទុកការងារនិងសេដ្ឋកិច្ច)

ច្បាប់ FFCRA តម្រូវឱ្យម្ចាស់អាជីវកម្ម ផ្តល់សិទ្ធិឈប់សម្រាកដោយមានជំងឺរហូតដល់ ៨០ម៉ោងក្នុង ២សប្តាហ៍ សម្រាប់រយៈពេល ១០សប្តាហ៍សម្រាប់ Family leave ។ ម្ចាស់អាជីវកម្ម និងបុគ្គលិកគួរសិក្សាលម្អិតបន្ថែមចំពោះករណីនេះ។ ឧទាហរណ៍ សិទ្ធិឈប់សម្រាកត្រូវតែផ្តល់ប្រាក់ឈ្នួល តែមិនមែនមានន័យថា ត្រូវបាន ១00% ពេញនោះទេ ។

ម្ចាស់អាជីវកម្មដែលត្រូវក្រោមច្បាប់នេះ មានសិទ្ធិស្នើសុំថ្លៃចំណាយដែលបានផ្តល់ជូនបុគ្គលិកដែលឈប់ដោយមានបៀវត្ស Family Leave និងការចំណាយថ្លៃព្យាបាលរបស់ពួកគេវិញ តាមរយៈ Refundable Tax Credits តាមរយៈច្បាប់ខាងលើ FFCRA ព្រមទាំងការចំណាយដាក់ស្តែងទាក់ទងនឹងការចំណាយលើការថែរក្សាសុខភាពរបស់បុគ្គលិកដែលបានឈប់សម្រាកទៀតផង ។

**តើបុគ្គលិកអាចត្រលប់ទៅធ្វើការវិញនៅពេលណា បន្ទាប់ពីគេបានឆ្លងកូវីដ១៩ ឬបានដាក់ឱ្យនៅដោយឡែកពីគេ ដោយមូលហេតុបានទាក់ទងផ្ទាល់នឹងអ្នកមានកូវីដ១៩? តើពួកគេត្រូវទៅធ្វើតេស្តដើម្បីបញ្ជាក់ថា គ្មានកូវីដ១៩ ដែរឬទេ?**

មណ្ឌលសុខភាព Snohomish Health District, Washington Department of Health and CDC មិនតម្រូវឱ្យពួកគេត្រូវទៅធ្វើតេស្តដើម្បីបញ្ជាក់ថា គ្មានកូវីដ១៩ទេ ដើម្បីត្រលប់ចូលធ្វើការវិញទេ។ ផ្ទុយមកវិញ គឺវាអាស្រ័យទៅលើរយៈពេល ។

តារាងពេលវេលា អាចរកបានតាមអនឡាញ ពាក់ព័ន្ធនឹងការណែនាំរយៈពេលដែលត្រូវឱ្យនៅដោយឡែកពីគេ។ រយៈពេលសំខាន់ៗមួយចំនួន៖

- បុគ្គលដែលមានវិជ្ជមានកូវីដ១៩ មិនគួរត្រលប់ទៅធ្វើការវិញទេ រហូតពួកគេពុំមានអការៈក្តៅខ្លួនយ៉ាងតិច ២៤ម៉ោង រោគសញ្ញាបានធូរស្បើយ និងហួសរយៈពេល ១0ថ្ងៃនៃរាប់ចាប់ពីថ្ងៃគេឈឺដំបូង។ បុគ្គលដែលគ្មានរោគសញ្ញា គួររង់ចាំឱ្យហួសរយៈពេល ១0ថ្ងៃសិន បន្ទាន់ពីតេស្តឃើញវិជ្ជមាន។
- បុគ្គលដែលមានការទាក់ទងផ្ទាល់នឹងអ្នកមានកូវីដ១៩ ប៉ុន្តែមិនមានវិជ្ជមានកូវីដ១៩ គួរនៅផ្ទះរយៈពេល ១៤ថ្ងៃ បន្ទាប់ពីថ្ងៃដែលគេចេញក្រៅចុងក្រោយ ទោះបីគេមិនមានរោគសញ្ញាក៏ដោយ ។

- ចំណុចសំខាន់ បើបុគ្គលណាកកំពុងមានរោគសញ្ញាកូវីដ១៩ (ក្អក ក្តៅខ្លួន ឈឺបំពង់កពិបាកដកដង្ហើម។ល។) ពួកគេមិនគួរទៅធ្វើការទេ ទោះបីលទ្ធផលតេស្តវិជ្ជមាន ឬអវិជ្ជមានក៏ដោយ។

ម្ចាស់អាជីវកម្មមិនត្រូវតម្រូវឱ្យបុគ្គលិកបង្ហាញលទ្ធផលអវិជ្ជមាន មុនពេលគេត្រលប់ទៅធ្វើការវិញ ឬចូលធ្វើការដំបូងទេ ដោយសារតែការធ្វើបែបនេះ នឹងធ្វើឱ្យមានការយឺតយ៉ាវ និងខាតពេល។ មេរោគអាចនៅពួនកន្លែងណាមួយច្រើនសប្តាហ៍ទៀត បន្ទាប់ពីជាសះស្បើយ និងអាចធ្វើឱ្យការធ្វើតេស្តមានលទ្ធផលមិនត្រឹមត្រូវ បន្ទាប់ពីករណីមេរោគនោះលែងឆ្លង។

បុគ្គលិកអាចមើលឯកសារពាក់ព័ន្ធរបស់ DOH ដើម្បីអាចជួយពួកគេតាមដានថាតើពេលណាពួកគេអាចត្រលប់ទៅធ្វើការវិញបាន។ បើសិនខ្លួនអ្នកមានប្រព័ន្ធការពារខ្សោយ ឬបើអ្នកមានជំងឺធ្ងន់ធ្ងរដោយសារកូវីដ១៩ កន្លែងមន្ទីរពេទ្យអាចនឹងណែនាំអ្នកឱ្យនៅដាក់ដោយឡែកពីគេរយៈពេលយូរជាងធម្មតា (អាចបន្ថែមដល់ ២០ថ្ងៃ បន្ទាប់ធ្លាក់ខ្លួនឈឺ) ។

**តើម្ចាស់អាជីវកម្មត្រូវផ្តល់ការឧបត្ថម្ភចំពោះកូន ឬកន្លែងសិក្សារបស់កូនបុគ្គលិកដែរឬទេ?**

តួនាទីមើលថែកូន និងការបិទសាលា បានធ្វើឱ្យមានការលំបាកសម្រាប់បុគ្គលិកដែលជាឪពុក-ម្តាយរបស់គេ ហើយម្ចាស់អាជីវកម្មត្រូវបង្កលក្ខណៈងាយស្រួលដើម្បីជួយតាមរយៈភាពបត់បែននៃម៉ោងធ្វើការ ការធ្វើការពីផ្ទះ និងការបង្កើតកន្លែងសមរម្យសម្រាប់ឱ្យកូនរបស់បុគ្គលិក។ ឪពុកម្តាយអាចទំនាក់ទំនងទៅសេវាកម្មមើលថែកុមារដោយឥតគិតថ្លៃ ដែលគ្រប់គ្រងដោយ Child Care Aware Family Center ។

ច្បាប់របស់រដ្ឋ តម្រូវឱ្យបុគ្គល ឬអង្គភាព រួមទាំងម្ចាស់អាជីវកម្ម ដែលបង្កើតជាកន្លែងសម្រាប់កុមារ ក្រៅពីលំនៅឋានរបស់កុមារ ត្រូវសុំការអនុញ្ញាតពី Department of Children, Youth and Families លើកលែងតែមានអនុញ្ញាតជាមុន។ ម្ចាស់អាជីវកម្ម និងអ្នកដទៃដែលមានបំណងផ្តល់កន្លែងសម្រាប់មើលថែកុមារ គួរយល់ថា បើគេតម្រូវឱ្យសុំការអនុញ្ញាត អ្នកអាចប្រឹក្សាជាមួយនឹង DCYF ។ សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធការស្នើសុំការអនុញ្ញាតលើកដំបូង អាចរកបាននៅ DCYF វេបសាយ ។

វាមានសារៈសំខាន់ណាស់ ដែលម្ចាស់អាជីវកម្មដែលរៀបចំកន្លែងមើលថែកុមារ និងឬការសិក្សាពីចម្ងាយ នៅកន្លែងធ្វើការ ឬទីកន្លែងណាមួយ ត្រូវយល់ដឹង និងអនុវត្តតាមសេចក្តីណែនាំរបស់ Washington State Department of Health’s child care, youth development and day camps guidelines ។ ការរៀបចំកន្លែងមើលថែ ឬបង្រៀនកុមារនៅកន្លែងធ្វើការ ត្រូវធ្វើតាមការណែនាំដើម្បីសុវត្ថិភាពកុមារ និងបុគ្គលិក។ ការកំណត់អាយុចូលរៀន នៅសាលារដ្ឋ ឬការរៀនតាមអនឡាញ ត្រូវស្របតាមលក្ខខណ្ឌអប់រំ និងសុវត្ថិភាព ចេញដោយ DOH and OSPI ។

ចំនួនកុមារ ដែលអាចអនុញ្ញាតឱ្យចូលរួមកម្មវិធីថែទាំកុមារ អាស្រ័យទៅលើថាតើវាគឺជាកន្លែងធ្វើថែទាំកុមារ ឬកន្លែងបង្រៀនកុមារនៅកន្លែងធ្វើការ ឬទីតាំងណាមួយ ត្រូវកំណត់ទៅតាមសេចក្តីណែនាំរបស់រដ្ឋខាងលើ រួមទាំងចំនួនកុមារ និងបុគ្គលមើលថែទាំកុមារ តាមការអនុញ្ញាតនៅពេលស្នើសុំ។ សូមកុំកំណត់ចំនួនកុមារ

ផ្អែកលើលក្ខខណ្ឌសេវាកម្មបច្ចេកទេសតម្រូវសម្រាប់អាជីវកម្មមួយ តែត្រូវអាស្រ័យលើចំនួនបុគ្គលិក។

**តើម្ចាស់អាជីវកម្មអាចរក្សាសុវត្ថិភាពសម្រាប់បុគ្គលិកដោយរបៀបណា អំឡុងពេលដំណើរការអាជីវកម្មធម្មតា?**

វាអាចមានវិធីច្រើនណាស់ដែលត្រូវដឹង តែខាងក្រោមនេះគឺជាវិធីសាស្ត្រមួយចំនួនៈ

- ធ្វើតាមការណែនាំ FAQ's for Employers & Businesses
- បុគ្គលិកត្រូវនៅផ្ទះបើមានរោគសញ្ញា ឬបើគេមានទំនាក់ទំនងផ្ទាល់នឹងអ្នកមានកូវីដ១៩
- ធ្វើការសម្អាតនិងសម្លាប់មេរោគគ្រប់ទីកន្លែង និងជាប្រចាំនៅកន្លែងធ្វើការ ជាពិសេសសម្ភារៈដែលប្រើប្រាស់រួមគ្នា
- ឱ្យបុគ្គលិកពាក់ម៉ាស់នៅ បើគេធ្វើការមានគ្នាច្រើន (កន្លែងធ្វើការ រថយន្ត កន្លែងការងារផ្ទាល់ ឬរក្សាគម្លាតពីអ្នកដទៃដោយដាក់សញ្ញាសម្គាល់)
- រក្សាគម្លាតរវាងបុគ្គលិក អតិថិជន នៅកន្លែងអាជីវកម្ម។ គេអាចយកស្ទីកឃ័រមកបិទសម្គាល់ ដើម្បីឱ្យពួកគេដឹងកន្លែងដែលត្រូវឈរ ឬរង់ចាំ ឬរៀបចំកន្លែងធ្វើការឱ្យបុគ្គលនៅឆ្ងាយពីគ្នា ឬយុទ្ធសាស្ត្រផ្សេងៗទៀតដែលសមស្របជាក់ស្តែង។
- អនុញ្ញាតឱ្យមានការធ្វើការពីចម្ងាយ(អនឡាញ)។ គួររៀបចំការធ្វើការពីចម្ងាយ ឬជ្រើសរើសល្អ សម្រាប់អ្នកមានហានិភ័យកូវីដ១៩ ខ្ពស់។
- អានបទបង្ហាញ Dr. Spitters for Economic Alliance Snohomish County ។
- ពិនិត្យមើលព័ត៍មានតាមរយៈ Links Available Here សម្រាប់ព័ត៍មាន និងសេចក្តីណែនាំនៃសហគ្រាស ដែលអ្នកធ្វើការ ។
- សូមចូលទៅ Business and Organizations page សម្រាប់ឯកសារពាក់ព័ន្ធបន្ថែមទៀត ។